## រឿងទី១០៖ យ៉ូណាស

**ខគម្ពីរ៖ យ៉ូណាស៤៖១១**

រីឯយើងវិញ តើមិនឲ្យយើងអាណិតក្រុងនីនីវេមហានគរនេះដូចម្ដេចបាន ដ្បិតមានប្រជាជនជាងដប់ពីរម៉ឺននាក់ ដែលមិនទាន់ដឹងខុសត្រូវ ព្រមទាំងមានហ្វូងសត្វច្រើនឥតគណនារស់នៅក្នុងក្រុងនេះទៀតផង»។

កាលពីយូរលង់ណាស់មកហើយ មានបុរសម្នាក់ឈ្មោះយ៉ូណាស់ គាត់រស់នៅក្នុងស្រុកអ៊ីស្រាអែល។ គាត់ គឺជាអ្នកដែលប្រកាសព្រះបន្ទូលព្រះជាម្ចាស់។

ថ្ងៃមួយ ព្រះជាម្ចាស់យាងមកជួបយ៉ូណាស់ ហើយមានបន្ទូលទៅគាត់ថា៖ «យ៉ូណាស់អើយ ចូរឯងធ្វើដំណើរទៅទីក្រុងនីនីវេ ប្រាប់ពួកគេឱ្យឈប់ធ្វើការអាក្រក់ទៅ»។

ទីក្រុងនីនីវេ គឺជាទីក្រុងដ៏ធំបំផុតមួយ។ ជាទីក្រុងដែលសម្បូរទៅដោយអ្នកមានអំណាច និងអ្នកមាន។

ប៉ុន្តែ អ្នកក្រុងនីនីវេទាំងនោះ មិនស្រឡាញ់អ្នកជិតខាង អាត្មានិយម រស់នៅសម្រាប់តែខ្លួនឯង។ ដូច្នេះហើយ ទើបយ៉ូណាសមិនចង់ធ្វើតាមការបង្គាប់របស់ព្រះជាម្ចាស់ទេ។

យ៉ូណាស មិនទៅនីនីវេតាមបង្គាប់របស់ព្រះជាម្ចាស់ទេ គាត់បានជិះទូកទៅតើស៊ើសវិញ មិនទៅនីនីវេទេ។

ទូកកំពុងតែបើកទៅមុខសុខៗ ស្រាប់តែភ្លាមនោះ ក៏មានខ្យល់ព្យុះបក់មកយ៉ាងខ្លាំងមកលើទូក!

មនុស្សនៅក្នុងទូក បានធ្វើការចាប់ឆ្នោតរើសអ្នកដែលធ្វើឱ្យមានខ្យល់ព្យុះនេះ។ អ្នកដែលត្រូវគេចាប់ឆ្នោតបាននោះគឺយ៉ូណាស។

មនុស្សទាំងអស់ បានបោះយ៉ូណាសចេញពីទូក ដើម្បីធ្វើឱ្យព្យុះស្ងប់។ ជារឿងគួរឱ្យភ្ញាក់ផ្អើល ពេលបោះយ៉ូណាសភ្លាម ខ្យល់ក៏ស្ងប់ រលកក៏ស្ងប់។

មានត្រីដ៏ធំមួយបានលេចមកលេបយ៉ូណាសដែលបានធ្លាក់ចូលទៅក្នុងទឹកសមុទ្រចូលទៅក្នុងពោះ។

ត្រីនេះ គឺជាត្រីដែលព្រះជាម្ចាស់បញ្ជូនមក។ យ៉ូណាសបាន អធិស្ឋាននៅក្នុងពោះត្រីអស់រយៈពេលបីថ្ងៃ។

ព្រះជាម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់យ៉ូណាស។ នៅថ្ងៃទីបីនោះ ត្រីបានខ្ជាក់យ៉ូណាសនៅលើដីគោកមួយ។

ទីបំផុត យ៉ូណាសក៏បានចេញពីក្នុងពោះត្រីមក។ យ៉ូណាសបានចេញទៅទីក្រុងនីនីវេដើម្បីប្រកាសព្រះបន្ទូលតាមការបង្គាប់របស់ព្រះជាម្ចាស់។

យ៉ូណាសបានដើរក្រសែកប្រកាសពីព្រះបន្ទូលយ៉ាងខ្លាំងៗពេញមួយថ្ងៃ។ អ្នកទីក្រុងនីនីវេ បានឮអ្វីដែលយ៉ូណាសប្រកាសហើយ មានការភ័យខ្លាចជាខ្លាំង។

ដូច្នេះ មនុស្សទូទាំងក្រុង មិនបរិភោគអ្វីទាំងអស់ ហើយអធិស្ឋានទៅព្រះជាម្ចាស់។

ព្រះជាម្ចាស់ទតឃើញថាជំនឿរបស់ពួកគេជាជំនឿពិតប្រាកដ ដូច្នេះ ទ្រង់ក៏លើកលែងទោសដល់ពួកគេ។

ហើយប្រជាជននីនីវេ និងទីក្រុងនីនីវេ ក៏មិនត្រូវបានបំផ្លាញដែរ។



**សកម្មភាពទី១** សូមគិតអំពីខ្លឹមសារមេរៀនដែលបានរៀនថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។



- សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (យ៉ូណាស៤:១១)

តើមិនឲ្យយើងអាណិត....?

## សកម្មភាពទី២

សូមកាត់រង្វង់ដែលមានរូបលោកយ៉ូណាស រួចយកទៅបិទភ្ជាប់លើពោះត្រីធំ។

**សម្ភារៈ៖ កន្ត្រៃ, កាវ**





រូបភាពរួចរាល់



KIDS GOD WORSHIP

www.kidsworship.kr

Selah

Ministerio de Publicación Cristiano

ឈ្មោះ